# ជំពូកទី២ : ក្របខ័ណ្ឌច្បាប់បរិស្ថាន

## ២.១- ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

១១. ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ត្រូវបានអនុម័តដោយរដ្ឋសភាជាតិ និងប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម ១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ។ ច្បាប់នេះមានគោលដៅ :

- ការពារលើកកំពស់គុណភាពបរិស្ថាន និងសុខភាពពលរដ្ឋ ដោយធ្វើការទប់ស្កាត់ការកាត់បន្ថយ និងការត្រួតពិនិត្យការបំពុល
- វាយតំលៃហេតុប៉ះពាល់បរិស្ថាន មុននឹងចេញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ចំពោះរាល់គំរោងដែលបានស្នើឡើង
- ធានាឱ្យមានការអភិរក្ស ការអភិវឌ្ឍន៍ ការគ្រប់គ្រង និងការប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរនូវធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា
- លើកទឹកចិត្ត និងផ្តល់លទ្ធភាពឱ្យសាធារណៈជនចូលរួមក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បង្ក្រាបអំពើទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន ។

១២. ទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់នេះបានតំរូវឱ្យបណ្តាក្រុមហ៊ុនទាំងអស់ ត្រូវរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង (IEIA) ឬ របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA) ។ ផ្អែកលើច្បាប់នេះ បានចែងនៅក្នុងមាត្រាទី៦ និង៧ នៃជំពូកទី៣ ដូចតទៅ :

- ***មាត្រា៦*** *: ការវាយតំលៃហេតុប៉ះពាល់បរិស្ថានត្រូវអនុវត្តលើគំរោង និងសកម្មភាពរបស់ឯកជន ឬ សាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតំលៃដោយក្រសួងបរិស្ថាន មុនដាក់ជូនរាជរដ្ឋាភិបាលសំរេច ។ ការវាយតំលៃនេះត្រូវអនុវត្តផងដែរ ចំពោះសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការហើយដែលពុំទាន់បានវាយតំលៃហេតុប៉ះពាល់បរិស្ថាននៅឡើយ ។ បែបបទនៃកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថានត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងបរិស្ថាន ។ ប្រភេទ និងទំហំគំរោង និងសកម្មភាពដែលបានស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ទាំងឯកជន និងសាធារណៈ ដែលត្រូវមានការវាយតំលៃហេតុប៉ះពាល់បរិស្ថាននេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន ។*
- ***មាត្រា៧*** *: ចំពោះរាល់ពាក្យសុំធ្វើគំរោងវិនិយោគ និងរាល់គំរោងដែលរដ្ឋស្នើឡើង ត្រូវមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង (IEIA) ឬ ការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ*

Draft

*(EIA) ដូចមានចែងក្នុងមាត្រា៦ នៃច្បាប់នេះ ។ ក្រសួងបរិស្ថានត្រូវពិនិត្យ និងផ្តល់យោបល់លើ (IEIA) ឬ (EIA) ទៅអង្គការមានសមត្ថកិច្ច ក្នុងរយៈពេលដូចបានកំណត់ក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។*

## ២-២ ច្បាប់ភូមិបាល

*១៣.* ច្បាប់ភូមិបាលនេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី២។ មាត្រាសំខាន់ៗដែលពាក់ព័ន្ធទៅនឹគំរោង គឺមានបង្ហាញដូចខាងក្រោម :

*- <u>មាត្រា ១</u> : ច្បាប់នេះ មានគោលដៅកំណត់អំពីរបបកម្មសិទ្ធិលើអចលនវត្ថុទាំងឡាយនៅព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាការពារសិទ្ធិនៃកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុស្របតាមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា ។*

*-<u>មាត្រា ៣</u> : ជនគ្រប់រូបត្រូវគោរពទ្រព្យសម្បត្តិរដ្ឋ និងកម្មសិទ្ធិឯកជនស្របច្បាប់លើអចលនវត្ថុ ។ ការគ្រប់គ្រងផ្នែករដ្ឋបាលសុរិយោដីលើអចលនវត្ថុដែលជាទ្រព្យសម្បត្តិរដ្ឋ និងការចេញប័ណ្ណកម្មសិទ្ធិលើអចលនវត្ថុទូទាំងព្រះរាជាណាចក្រកម្ពុជា ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ បទបញ្ជា និងនីតិវិធីនៃការគ្រប់គ្រងអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ នឹងត្រូវកំណត់ដោយអនុក្រឹត្យ ។*

*- <u>មាត្រា ៧</u> : របបកម្មសិទ្ធិលើអចលនវត្ថុមុនឆ្នាំ១៩៧៩ មិនត្រូវបានទទួលស្គាល់ ។*

*-<u>មាត្រា ១២</u>:រដ្ឋជាកម្មសិទ្ធិករនៃទ្រព្យសម្បត្តិទាំងឡាយក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចែងក្នុងមាត្រា៥៨ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ និងទ្រព្យនិទាយាទភាពទាំងអស់ ឬទ្រព្យដែលម្ចាស់ប្រគល់ឱ្យរដ្ឋ ដោយស្ម័គ្រចិត្ត ឬទ្រព្យដែលមិនមែនជាកម្មវត្ថុនៃការយកធ្វើជារបស់ឯកជនតាមច្បាប់ ឬមិនមែនជាទ្រព្យ ដែលកំពុងកាន់កាប់ជារបស់ឯកជនស្របតាមបទបញ្ញត្តិនៃជំពូកទី៤ នៃច្បាប់នេះ ។*

*- <u>មាត្រា ១៥</u> : រាប់ចូលក្នុងទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ*

Draft

- ទ្រព្យទាំងឡាយដែលបង្ហាញនូវការកើតឡើងពីធម្មជាតិដូចជា ព្រៃឈើ ផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន បឹងធម្មជាតិ ច្រាំងទន្លេ ដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន និង ត្រើយសមុទ្រ ។
- ទ្រព្យទាំងឡាយដែលជាកម្មវត្ថុនៃការរៀបចំពិសេសសំរាប់ប្រយោជន៍ទូទៅដូចជា តីរវ៉ាន កំពង់ផែ ផ្លូវដែក ស្ថានីយ៍រថភ្លើង និងព្រលានយន្តហោះ ។
- ទ្រព្យទាំងឡាយ ដែលត្រូវបានដាក់ឱ្យប្រើជាសាធារណៈតាមស្ថានភាពពីកំណើត ឬក្រោយពីបានរៀបចំដូចជា ផ្លូវថ្នល់ ផ្លូវលំ ផ្លូវរទេះ ផ្លូវដើរ សួនច្បារ និងឧទ្យានសាធារណៈ និងដីចំណី។
- ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យដំណើរការសំរាប់សេវាសាធារណៈដូចជា សាលារៀន ឬអគារសិក្សាសាធារណៈ អគាររដ្ឋបាល មន្ទីរពេទ្យសាធារណៈទាំងឡាយ ។
- ទ្រព្យទាំងឡាយ ដែលបង្កើតជាដែនបំរុងធម្មជាតិការពារដោយច្បាប់ ។
- បេតិកភ័ណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រ ។
- អចលនវត្ថុជាព្រះរាជទ្រព្យដែលមិនមែនជាទ្រព្យសម្បត្តិឯកជនរបស់ព្រះរាជវង្សានុវង្ស ។
- អចលនវត្ថុជាព្រះរាជទ្រព្យត្រូវបានថែរក្សាដោយព្រះមហាក្សត្រកំពុងគ្រងរាជ ។

*-មាត្រា ១៦: ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនអាចលក់ដូរបានឡើយ ហើយកម្មសិទ្ធិនៃទ្រព្យទាំងនោះមិនអាចកំណត់អាយុកាលបានទេ ។*

- ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនអាចឋិតនៅក្រោមការកាន់កាប់ដោយលទ្ធកម្មពិសេសនៃជំពូកទី៤ នៃច្បាប់នេះបានទេ ។

- ប៉ុន្តែទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋអាចជាកម្មវត្ថុនៃការអនុញ្ញាតិឱ្យកាន់កាប់ ឬប្រើប្រាស់ជាបណ្តោះអាសន្នមិនទៀង ហើយអាចដកហូតវិញបាន បើមិនបានបំពេញកាតព្វកិច្ចបង់ពន្ធផ្សេងៗ លើកលែងតែបានអនុញ្ញាតតាមជំពូកទី៣ នៃច្បាប់នេះ ។ ការអនុញ្ញាតទាំងនេះមិនអាចប្រែក្លាយទៅជាកម្មសិទ្ធិ ឬជាសិទ្ធិភឿ្នកជាប្រយោជន៍ដល់អ្នកកាន់កាប់ទ្រព្យទាំងនេះបានឡើយ ។

- ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ នៅពេលបាត់បង់ប្រយោជន៍សាធារណៈអាចត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋតាមរយៈអនុបយោគ ។

*- **មាត្រា ១៨** : ត្រូវទុកជាមោឃៈ និងគ្មានអានុភាព ហើយមិនអាចត្រូវបានធ្វើនិយ័តកម្ម ទោះក្នុងរូបភាពណាក៏ដោយនូវ :*

- រាល់ការចូលកាន់កាប់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ និងរាល់ការបំប្លែងការកាន់កាប់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទៅជាសិទ្ធិ កម្មសិទ្ធិ ទោះបីការកាន់កាប់ និងការបំប្លែងនេះ

កើតឡើងនៅពេលណាក៏ដោយ ដែលមិនសមស្របតាមលិខិតបទដ្ឋានគតិយុត្តិ និងនីតិវិធី ដែលបានកំណត់កន្លងមក ។

- រាល់ការបំប្លែងទៅជាសិទ្ធិកម្មសិទ្ធិនៃដីសម្បទាន ទោះជាការបំប្លែងនោះកើតឡើងមុនពេលច្បាប់នេះ ចូលជាធរមានក៏ដោយ លើកលែងតែសម្បទាន ដែលឆ្លើយតបទៅនឹងប្រយោជន៍សង្គម ។
- រាល់សម្បទានមិនស្របនឹងបញ្ញត្តិទាំងឡាយនៃជំពូកទី ៥ ។
- រាល់ការចូលកាន់កាប់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ទោះជាតាមរូបភាពណាក៏ដោយ ដែលបានកើតឡើងក្រោយច្បាប់នេះចូលជាធរមាន ។

- *<u>មាត្រា ៣៣</u> : ក្នុងករណីមានការដកហូតអចលនវត្ថុដោយហិង្សា ឬដោយប្រើអំណាចរំលោភរបស់អាជ្ញាធរ អចលនវត្ថុនោះត្រូវបានបង្វិលមករដ្ឋវិញ ហើយមិនអាចជាកម្មវត្ថុនៃការកាន់កាប់ថ្មីបានឡើយ ប្រសិនបើគ្មានបណ្តឹងទាមទារពីភាគីស្របច្បាប់នៃអចលនវត្ថុដែលត្រូវបានដកហូត ។ បណ្តឹងទាមទារនេះមានរយៈពេល ៣ (បី) ឆ្នាំ ចាប់ពីថ្ងៃដែលរដ្ឋប្រកាសដកហូត ។*

- *<u>មាត្រា ៣៤</u> : អ្នកកាន់កាប់ថ្មីលើអចលនវត្ថុរបស់នីតិបុគ្គលសាធារណៈ ឬរបស់បុគ្គលឯកជនដោយគ្មានប័ណ្ណក្រោយច្បាប់នេះចូលជាធរមាន ត្រូវចាត់ទុកជាអ្នកកាន់កាប់ដោយខុសច្បាប់ ហើយត្រូវទទួលទោស ដូចមានចែងក្នុងមាត្រា២៥៩ នៃច្បាប់នេះ ។*

- *<u>មាត្រា ៣៥</u> : មានតែអាជ្ញាធរមានសមត្ថកិច្ចក្នុងនាមរដ្ឋ និងនីតិបុគ្គលសាធារណៈប៉ុណ្ណោះ ដែលអាចអោយអ្នកកាន់កាប់អចលនវត្ថុគ្មានប័ណ្ណ ឬមានប័ណ្ណមិនគ្រប់គ្រាន់ចាកចេញពីទីតាំងអចលនវត្ថុនោះ ។ សាមញ្ញជន ឬអាជ្ញាធរដែលមិនតាងនាមរដ្ឋ ឬនីតិបុគ្គលសាធារណៈគ្មានសមត្ថកិច្ចដេញអ្នកកាន់កាប់ ដោយសន្តិភាពមានប័ណ្ណត្រឹមត្រូវដោយប្រើកម្លាំងបានឡើយ ។ ការដេញអាចធ្វើបានតែតាមការបង្គាប់របស់តុលាការ យោងតាមបណ្តឹងរបស់បុគ្គលដែលបានប្តឹងទាមទារទ្រព្យ ។ តុលាការត្រូវពិនិត្យបញ្ជាក់រូបភាព ប្រភព កាលបរិច្ឆេទ និងលក្ខខ័ណ្ឌទាំងឡាយនៃប័ណ្ណ ដែលបានបង្ហាញ ។ តុលាការមិនអាចប្រកែកក្នុងការបង្គាប់ឱ្យចាកចេញ ដើម្បីជាប្រយោជន៍ដល់បុគ្គលដែលបង្ហាញប័ណ្ណត្រឹមត្រូវ និងពេញលេញរបស់សុរិយោដីបានឡើយ ។*

- <u>មាត្រា ៤៥</u> : *ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចមិនព្រមចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ អ្នកកាន់កាប់អចលនវត្ថុនោះអាចធ្វើពាក្យប្តឹងទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។*

## ២-៣ ច្បាប់ការងារ

*១៤.* ច្បាប់ស្តីពីការងារ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៩៧ នាសម័យប្រជុំលើកទី៧ នីតិកាលទី១ ដែលមានន័យសេចក្តីពាក់ព័ន្ធទៅនឹងគំរោងមានបង្ហាញដូចខាងក្រោម :

*- មាត្រា ១ : ច្បាប់នេះគ្រប់គ្រងរាល់ទំនាក់ទំនងដែលកើតចេញពីកិច្ចសន្យាការងាររវាងនិយោជក និង កម្មករនិយោជិក ដើម្បីយកមកអនុវត្តលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទោះបីកិច្ចសន្យានោះធ្វើឡើងនៅទីណាក៏ដោយ ទោះបីភាគីទាំងនោះមានសញ្ជាតិជាអ្វី ហើយស្នាក់នៅទីណាក៏ដោយ ។ ច្បាប់នេះអនុវត្តចំពោះសហគ្រាស ឬគ្រឹះស្ថាន ឧស្សាហកម្មរ៉ែ ពាណិជ្ជកម្ម សិប្បកម្ម សេវាកម្ម ដឹកជញ្ជូនតាមផ្លូវគោក ឬតាមផ្លូវទឹក ទោះជាប្រយោជន៍សាធារណៈ ពាក់កណ្តាលសាធារណៈ ឬឯកជន ក្រៅសាសនា ឬក្នុងសាសនាក៏ដោយ ទោះមានលក្ខណៈជាការបង្រៀនវិជ្ជាជីវៈ ឬជាការកុសលក៏ដោយព្រមទាំងវិជ្ជាជីវៈសេរីនៃសមាគម ឬក្រុមប្រភេទណាក៏ដោយ ។*

*- មាត្រា ៣ : កម្មករនិយោជិក តាមន័យនៃច្បាប់នេះគឺជនគ្រប់ប្រភេទ និងគ្រប់សញ្ជាតិដែលបានចុះកិច្ចសន្យាធ្វើការយកកំរៃក្រោមការដឹកនាំ និងគ្រប់គ្រងរបស់បុគ្គលម្នាក់ទៀតជារូបវន្តបុគ្គល ឬនីតិបុគ្គលជាសាធារណៈ ឬឯកជន ។ ដើម្បីបញ្ជាក់ឱ្យបានច្បាស់អំពីលក្ខនិកៈ គតិយុត្តិនៃកម្មករនិយោជិក ព្រមទាំងមិនត្រូវគិតពីចំនួនប្រាក់ឈ្នួលតិច រឺច្រើនទេ ។*

*-មាត្រា ៥ : និយោជិក ឬអ្នកជួយ គឺជនដែលមានកិច្ចសន្យាជួយធ្វើការបុគ្គលណាម្នាក់ដោយយកកំរៃ ប៉ុន្តែគ្មានធ្វើហត្ថកម្មពេញទី ឬក៏គ្រាន់តែជួយធ្វើហត្ថកម្មជាបន្ទាប់បន្សំប៉ុណ្ណោះ ។*

*- មាត្រា ៦ : កម្មករ គឺជាអ្នកធ្វើការយកឈ្នួល ក្រៅពីអ្នកបំរើនៅក្នុងផ្ទះ និងនិយោជិក.ពោលគឺជនដែលធ្វើការភាគច្រើនខាងហត្ថកម្មយកកំរៃក្រោមការដឹកនាំនៃនិយោជក ឬតំណាងនៃជននេះ ។*

*- មាត្រា ១១ : តាមរបៀបបើកប្រាក់ឈ្នួល កម្មករនិយោជិក ត្រូវបែងចែកដូចតទៅនេះ :*

- កម្មករនិយោជិក ធ្វើការយកប្រាក់ឈ្នួលតាមពេល "ប្រចាំខែ ប្រចាំថ្ងៃ ប្រចាំម៉ោង" ដែលគេត្រូវបើកប្រាក់ឈ្នួលឱ្យរាល់ថ្ងៃ ឬរាប់ពេលមិនហួសពីដប់ថ្ងៃ ឬមួយខែ ។
- កម្មករនិយោជិក ធ្វើការយកប្រាក់ឈ្នួលតាមបរិមាណផលិតផល ឬម៉ៅការ ។
- កម្មករនិយោជិក ធ្វើការយកកំរៃជើងសារ ។

***-មាត្រា ១៤*** : និយោជកត្រូវតែមានច្បាប់ការងារយ៉ាងហោចណាស់មួយច្បាប់ សំរាប់សេចក្តីត្រូវការនៃកម្មករ និយោជិករបស់ខ្លួន ហើយជាពិសេសសំរាប់តំណាងនៃកម្មករនិយោជិកនៅគ្រប់សហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា ១ នៃច្បាប់នេះ ។

***-មាត្រា ១៦*** : ការជួលមនុស្សឱ្យធ្វើការងារដើម្បីកាត់ជំពាក់ ត្រូវហាមឃាត់ ។

***-មាត្រា ១៧*** : និយោជកទាំងអស់ដែលត្រូវអនុវត្តច្បាប់ការងារនេះ ត្រូវធ្វើសេចក្តីប្រកាសជូនដំណឹងទៅក្រសួងទទួលបន្ទុកវិស័យការងារនៅពេលបើកសហគ្រាស គ្រឹះស្ថាន ។ សេចក្តីប្រកាសជូនដំណឹងនេះហៅថា សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស គ្រឹះស្ថាន ដែលត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ និងដាក់ជូនក្រសួងទទួលបន្ទុកវិស័យការងារនៅមុនពេលបើកសហគ្រាស គ្រឹះស្ថានជាស្ថាពរ ។

***-មាត្រា ១៨*** : ចំពោះការបិទសហគ្រាស និយោជកក៏ត្រូវធ្វើសេចក្តីប្រកាសជូនដំណឹងទៅក្រសួងទទួលបន្ទុកវិស័យការងារដែរ ក្នុងរយៈពេលសាមសិបថ្ងៃ បន្ទាប់ពីថ្ងៃបិទសហគ្រាសនោះ ។

***-មាត្រា ២១*** : នៅរាល់ពេលដែលទទួលឱ្យធ្វើការ ឬបញ្ឈប់កម្មករនិយោជិកណាម្នាក់ និយោជកត្រូវធ្វើសេចក្តីប្រកាសជូនដំណឹងទៅក្រសួងទទួលបន្ទុកវិស័យការងារ ។ សេចក្តីប្រកាសជូនដំណឹងនេះត្រូវតែធ្វើជាលាយលក្ខណ៍អក្សរក្នុងរយៈពេលដប់ប្រាំថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃទទួលឱ្យធ្វើការ ឬបញ្ឈប់ឱ្យធ្វើការ ។

Draft

***-មាត្រា ៣២*** : ជនដែលមានសញ្ជាតិខ្មែរ ធ្វើការយកឈ្នួលពីនិយោជកណាមួយត្រូវតែមានសៀវភៅការងារ ។ ជនណាក៏ដោយមិនអាចប្រើកម្មករនិយោជិកដែលមិនប្រតិបត្តិតាមបទបញ្ញត្តិនៃកថាខ័ណ្ឌខាងលើនេះ បានទេ ។

***-មាត្រា ៦៥*** : កិច្ចសន្យាការងារ គឺជាកិច្ចសន្យាដែលបង្កើតឱ្យមានការទាក់ទងផ្នែកការងាររវាងកម្មករនិយោជិក និងនិយោជក ។ កិច្ចសន្យានេះត្រូវនៅក្រោមវិធានអាជ្ញាគតិ ហើយអាចនឹងធ្វើទៅតាមទំរង់ដែលភាគីទាំងសងខាងព្រមព្រៀងគ្នា ។

***-មាត្រា ២៤៨*** : ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ដែលកើតឡើងដោយធ្វើការ ឬក្នុងពេលដែលធ្វើការ ទោះដោយហេតុយ៉ាងណាក៏ដោយ ហើយទោះជាមានកំហុសមកពីកម្មករនិយោជិក ឬគ្មានក៏ដោយ គឺគ្រោះថ្នាក់ដែលធ្លាក់លើរូបកាយកម្មករ និយោជិកក្នុងពេលធ្វើការឱ្យនិយោជក

*ឬទោសយកសហគ្រាស ឬធ្លាក់លើសិស្សវិជ្ជាជីវៈមានល្អលក្តី ឥតល្អលក្តី កាន់មុខងារជាអ្វីទៅទីកន្លែងណាក៏ដោយ ។ ម្យ៉ាងវិញទៀត ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារដែលចំពោះគ្រោះថ្នាក់ណាដែលធ្លាក់លើកម្មករ និយោជិកក្នុងពេលដែលសាម៉ីខ្លួន ធ្វើដំណើរពីលំនៅស្ថានខ្លួនត្រង់ឆ្ពោះទៅកន្លែង ធ្វើការ ឬវិលមកវិញដោយគ្មានឈប់ ឬដោយគ្មានវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ឬក្រៅពីការងារដែលគេតំរូវឱ្យទៅ ។*

*-__មាត្រា ២៥៣__ : ក្នុងករណីដែលមានគ្រោះថ្នាក់ដល់ស្លាប់ ឬគ្រោះថ្នាក់ដែលបណ្តាលឱ្យបាត់បង់សមត្ថភាពពលកម្មជាអចិន្ត្រៃយ៍ ប្រាក់បំណាច់ត្រូវបើកឱ្យជនរងគ្រោះ ឬអ្នកសិទ្ធិវន្តជាធនលាភ ។ ត្រូវឱ្យប្រាក់បំណាច់បន្ថែមដល់អ្នករងគ្រោះណាដែលតំរូវឱ្យមានមនុស្សដទៃម្នាក់នៅថែទាំខ្លួនជានិច្ច ។*

*-__មាត្រា ២៥៤__ : អ្នករងគ្រោះថ្នាក់ការងារត្រូវមានសិទ្ធិទទួលការពិនិត្យជំងឺ ( ការផ្តល់ជាវត្ថុ ការព្យាបាលជំងឺ និងការផ្តល់ថ្នាំ ព្រមទាំងកន្លែងសំរាកព្យាបាលជាដើម) និងការព្យាបាលខាងវះកាត់ និងផ្តល់បន្ថែមវត្ថុណា ដែលចាំបាច់បន្ទាប់ពីគ្រោះថ្នាក់ទាំងនោះ ។*

## ២-៤ ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ

**១៥.** ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គ លើកទី៥ នីតិកាលទី១ ។

**១៦.** ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ការប្រើប្រាស់អណ្តូងរ៉ែ ព្រមទាំងរាល់សកម្មភាពទាំងឡាយ ដែលទាក់ទងទៅនឹងប្រតិបត្តិការធនធានរ៉ែនៅព្រះរាជាណាចក្រកម្ពុជា ។ លើកលែងតែប្រតិបត្តិការប្រេងកាត និងឧស្ម័នត្រូវស្ថិតនៅក្រោមច្បាប់មួយដោយឡែក ។

**១៧.** ពាក់ព័ន្ធទៅនឹងកិច្ចការពារបរិស្ថាន ត្រង់មាត្រា២១ ជំពូកទី៥ នៃច្បាប់នេះបានបញ្ជាក់ថា :

- ការពារបរិស្ថានដូចមានលំអិតក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន ផែនការគ្រប់គ្រងបរិស្ថាន ផែនការលុបអណ្តូងរ៉ែ និងការធានាផ្នែកហិរញ្ញវត្ថុ ។
- ធានាការពារសុខភាព និងសុវត្ថិភាពពលករដែលនឹងលំអិតក្នុងកម្មវិធីផែនការអណ្តូងរ៉ែ កម្មវិធីសុខភាពនិងសុវត្ថិភាពក្នុងអណ្តូងរ៉ែ រាប់បញ្ចូលទាំងការការពារគ្រោះថ្នាក់ បែបបទរាយការណ៍ស្តីពីគ្រោះថ្នាក់នេះ ។

- ការពារសុវត្ថិភាពដល់សាធារណជន នៅក្នុង និងជុំវិញតំបន់អណ្តូងរ៉ែ ដែលនឹងលំអិតក្នុងផែនការអណ្តូងរ៉ែ ។
- ធ្វើការអប់រំបណ្តុះបណ្តាល និងផ្តល់ការងារដល់ប្រជាពលរដ្ឋខ្មែរ ដែលនឹងលំអិតក្នុងកម្មវិធីផ្តល់ការងារ អប់រំ បណ្តុះបណ្តាល ។

## ២-៥ ច្បាប់ស្តីពីជលផល

១៨: ច្បាប់ស្តីពីជលផល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ៣០ ខែ មិនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៣ និងព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យ និងផ្តល់យោបល់ លើអត្ថបទច្បាប់នេះ ស្របតាមមាត្រា ១១៣ថ្មីនៃរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ:

*- មាត្រា ១: ច្បាប់នេះមានគោលបំណងធានានូវការគ្រប់គ្រងជលផល និងធនធានជលផល ជំរុញកិច្ចអភិវឌ្ឍន៍វារីវប្បកម្ម ផលិតកម្ម និងការកែច្នៃលើកស្ទួយជីវភាពរស់នៅរបស់ពលរដ្ឋ ក្នុងសហគមន៍មូលដ្ឋានដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន រួមទាំងការអភិរក្សជីវចម្រុះផងទាំងមរតកវប្បធម៌ធម្មជាតិផងប្រកបដោយនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។*

*- មាត្រា ២: ច្បាប់នេះមានវិសាលភាពអនុវត្តលើជលផលទាំងអស់ ទាំងប្រភេទជលផលដែលកើតឡើងដោយធម្មជាតិទាំងផលកែច្នៃ និងទាំងវារីវប្បកម្ម ។ រដ្ឋធានាសិទ្ធិប្រើប្រាស់ធនធានជលផលជាប្រពៃណីរបស់សហគមន៍មូលដ្ឋានក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ឬ ច្បាប់ពាក់ព័ន្ធផ្សេងទៀត ។*

*- មាត្រា ៤: ធនធានជលផលមានសរីរាង្គទឹកសាប និងសមុទ្រ ជាសត្វ និងរុក្ខជាតិ មានជីវិត ឬគ្មានជីវិត ជាអាទិ៍មច្ឆាជាតិ សិប្បីសត្វ ថលជលិក សត្វបាលសត្វ ឧរង្គសត្វ ថនិកសត្វ សត្វឥតឆ្អឹងកងផ្សេងទៀត ដែលបង្កកំណើតនៅក្នុងទឹក ឬរស់គុង សារាយ ស្មៅសមុទ្រ ផ្កាថ្ម ព្រៃលិចទឹក ព្រមទាំងព្រៃកោងកាងជាដើម ។*

*- មាត្រា ៦: រដ្ឋបាលជលផល គឺជាអាជ្ញាធររដ្ឋាភិបាលដែលចំណុះក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានភារកិច្ចគ្រប់គ្រងជលផល និងធនធានជលផលស្របតាមគោលនយោបាយវិស័យជលផលជាតិ និងខ្លឹមសារនៃច្បាប់នេះ ។ រដ្ឋបាលជលផលមានរចនាសម្ព័ន្ធគ្រប់គ្រងចាត់តាំងមួយឯកភាពទូទាំងប្រទេសជាខ្សែរយៈបណ្តោយ ដែលបែងចែកជាថ្នាក់ កណ្តាល អធិការដ្ឋាន ខណ្ឌ ផ្នែក និងសង្កាត់រដ្ឋបាលជលផល ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពរបស់រដ្ឋបាលជលផល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។*

*- មាត្រា ១៧: ដើម្បីជំរុញការអប់រំប្រជាពលរដ្ឋអោយយល់ពីសារៈសំខាន់ និងផលប្រយោជន៍នៃផលផលទិវាសែងត្រី ឬវារីសត្វជាប្រពៃណីជាតិហៅថា **ទិវាមច្ឆជាតិ** ត្រូវប្រារព្វធ្វើឡើងនៅថ្ងៃទី ០១ ខែកក្កដា ជារៀងរាល់ឆ្នាំ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ឬព្រះរាជតំណាង ។*

*- មាត្រា ១៨: តំបន់គ្រប់គ្រងជលផលជាអាទិ៍ តំបន់ទឹកជូរ អន្លង់ជ្រៅៗនៅតាមដងទន្លេ បឹង បឹងទន្លេសាប ព្រៃលិចទឹក តំបន់កោះ តំបន់ស្មៅសមុទ្រ តំបន់ផ្កាថ្ម និងព្រៃកោងកាង ដែលជាកន្លែងមានសារៈសំខាន់ដល់និរន្តរភាពនៃធនធានជលផល ត្រូវរៀបចំចាត់ថ្នាក់ជាកន្លែងការពារ និងអភិរក្សធនធានជលផល ។*

## ២-៦ ច្បាប់ស្តីពី ជីវសុវត្ថិភាព

**១៩.** ច្បាប់ស្តីពីជីវសុវត្ថិភាព ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋសភា លើកទី៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយកាលពី ថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ:

- *មាត្រា ១ : ច្បាប់នេះមានគោលបំណង អនុវត្តគោលការណ៍ប្រុងប្រយ័ត្នស្តីពីជីវសុវត្ថិភាព ទប់ស្កាត់ ផលប៉ះពាល់អវិជ្ជមានទៅលើការអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា ដែលបណ្តាលមកពីការផលិត ការដឹកជញ្ជូនឆ្លងដែន ការអភិវឌ្ឍន៍ ការលើកដាក់ ការផ្ទេរ ការប្រើប្រាស់ ការស្តុកទុក និងការបញ្ចេញសារពាង្គកាយកែច្នៃរស់ដែលបង្កើតឡើងដោយជីវបច្ចេកវិទ្យាទំនើប ។ ធានាប្រសិទ្ធិភាពនៃការអភិរក្ស និងការប្រើប្រាស់ជីវៈចម្រុះដោយនិរន្តរភាព ព្រមទាំងយកចិត្តទុកដាក់ចំពោះហានិភ័យដល់សុខភាពមនុស្ស ធ្វើអោយមានតម្លាភាពក្នុងនីតិវិធីពិនិត្យ និងក្នុងការធ្វើសេចក្តីសំរេចចំពោះសារពាង្គកាយកែច្នៃរស់ និងសកម្មភាពទាំងឡាយដែលទាក់ទងនឹងសារពាង្គកាយ កែច្នៃរស់ ។ លើកកំពស់ការយល់ដឹងអំពីជីវបច្ចេកវិទ្យាទំនើបសំដៅទប់ស្កាត់ហានិភ័យពីការប្រើប្រាស់ និងការបញ្ចេញសារពាង្គកាយកែច្នៃរស់ទៅក្នុងបរិស្ថាន និងសុខភាពមនុស្ស ។*

- *មាត្រា ៣: ច្បាប់នេះអនុវត្តចំពោះការនាំចូល និងនាំចេញ ការប្រើប្រាស់ក្នុងព្រំដែនកំណត់ ការបញ្ចូលសារពាង្គកាយកែច្នៃរស់ទៅក្នុងបរិស្ថានដោយចេតនា និងការប្រើប្រាស់ផ្ទាល់ដើម្បីជាម្ហូបអាហារ ឬចំណីសត្វ ឬដើម្បីកែច្នៃរស់ ដែលអាចប៉ះពាល់ដល់ការអភិរក្ស និងការប្រើប្រាស់ជីវៈចម្រុះដោយនិរន្តរភាព ព្រមទាំងបញ្ហាសុខភាពមនុស្សផងដែរ ។ ច្បាប់នេះនឹងមិន*

*អនុវត្តចំពោះៈ សារពាង្គកាយកែថ្នៃរស់ សំរាប់ប្រើជាឱសថដែលមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិដែលពាក់ព័ន្ធ ។ សារពាង្គកាយកែថ្នៃរស់ដែលគ្រាន់តែដឹកជញ្ជូនឆ្លងកាត់ តែពុំមានទិសដៅយកមកប្រើនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ប្រភេទសារពាង្គកាយកែថ្នៃរស់មួយចំនួនទៀតដែលត្រូវបានលើកលែងដោយស្ថាប័នមានសមត្ថកិច្ច ។ ផលិតផលសារពាង្គកាយកែថ្នៃរស់មិនមានជីវិត ឬក៏សមាសភាពនៃសារពាង្គកាយអជីវិតកែថ្នៃសេនេទិច ។*

- *មាត្រា ៥: រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលបានផ្តល់ដំណឹងថាមានបំណងធ្វើសកម្មភាព ឬ ប្រតិបត្តិការទាក់ទងនឹងសារពាង្គកាយកែថ្នៃរស់ ដូចជា ការប្រើប្រាស់ក្នុងព្រំដែនកំណត់ ការបញ្ចូលទៅក្នុងបរិស្ថានដោយចេតនា និងឬ ដើម្បីប្រើប្រាស់ដោយផ្ទាល់ធ្វើជាម្ហូបអាហារ ជាចំណីសត្វ ឬ ដើម្បីកែច្នៃនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានការឯកភាពជាមុនពីក្រសួងបរិស្ថាន មុននឹងសុំការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធ ។ សកម្មភាព ឬ ប្រតិបត្តិការណាមួយដែលពាក់ព័ន្ធនឹងសារពាង្គកាយកែថ្នៃរស់ ក្រោមបទបញ្ញត្តិនៃច្បាប់នេះត្រូវអនុវត្តស្របតាមស្តង់ដារ និងវិធានការស្តីពីការគ្រប់គ្រង និង ត្រួតពិនិត្យអំពីហានិភ័យដូចដែលបានកំណត់ក្នុងនីតិវិធីស្តីពីការវាយតំលៃហានិភ័យ ដូចបានចែងក្នុងជំពូកទី៥ ហើយនឹងមានចែងលម្អិតដោយប្រកាសរបស់ក្រសួងបរិស្ថាន បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយស្ថាប័នមានសមត្ថកិច្ច ដែលពាក់ព័ន្ធ ។*

- *មាត្រា ៦: ក្រសួងបរិស្ថាន ដោយសហការជាមួយក្រសួងពាក់ព័ន្ធត្រូវត្រួតពិនិត្យរាល់សកម្មភាព និង ប្រតិបត្តិការដែលពាក់ព័ន្ធនឹងសារពាង្គកាយកែថ្នៃរស់ ដែលបានបញ្ញត្តិនៃច្បាប់នេះ ។*

- *មាត្រា ៧: ក្នុងការទទួលខុសត្រូវជាស្ថាប័នបង្គោលជាតិ ដូចបានចែងក្នុងមាត្រា៦ ខាងលើនេះ ក្រសួងបរិស្ថានត្រូវធ្វើជាស្ថាប័នទំនាក់ទំនងដំបូងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង លេខាធិការដ្ឋានអនុសញ្ញាជីវៈចម្រុះ ។ ក្នុងតួនាទីជាស្ថាប័នមានសមត្ថកិច្ចរបស់ជាតិ ក្រសួងបរិស្ថានត្រូវទទួលខុសត្រូវក្នុងការបំពេញមុខងាររដ្ឋបាល ដែលបានតំរូវសំរាប់អនុវត្តច្បាប់នេះ ។ មុខងារទាំងនេះរួមមាន ការជូនដំណឹងទាន់ពេលវេលាទៅប្រទេសដទៃទៀត និងមណ្ឌលចែកចាយពិតមានជីវសុវត្ថិភាព ព្រមទាំងអង្គការអន្តរជាតិ ដែលពាក់ព័ន្ធទាំងឡាយក្នុងករណីមានហេតុការណ៍ណាមួយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបណ្តាលមកពីចលនាឆ្លងដែនណាមួយដោយអចេតនានៃសារពាង្គកាយកែថ្នៃរស់ ។ មន្ត្រីរបស់ក្រសួងបរិស្ថានដែលត្រូវបានចាត់តាំងដោយសហការជាមួយមន្ត្រីជំនាញ នៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ អាចធ្វើ*

Draft

*អធិការកិច្ច អាចប្រមូលយកគំរូតាង ឬ វត្ថុតាង ដើម្បីសំរួលដល់ការស៊ើបអង្កេតក្នុងទីតាំងដែលបាន ឬកំពុងមានសកម្មភាព ឬប្រតិបត្តិការទាក់ទងនឹងសារពាង្គកាយកែច្នៃរស់ ។*

- *មាត្រា ១១: ការនាំចូលសារពាង្គកាយកែច្នៃរស់មកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីបញ្ចូលទៅក្នុងបរិស្ថានដោយចេតនា ត្រូវបានតំរូវអោយមានការវាយតំលៃហានិភ័យ ព្រមទាំងមានការយល់ព្រមពីក្រសួងបរិស្ថានជាមុន មុននឹងស្នើសុំការអនុញ្ញាតនាំចូលពីស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធ ។ ម្ចាស់ស្នើត្រូវដាក់ពាក្យទៅក្រសួងបរិស្ថាន អំពីគោលបំណងនៃការនាំចូលរបស់ខ្លួន ។*

- *មាត្រា ១៩ : អ្នកនាំចេញសារពាង្គកាយកែច្នៃរស់ ពីព្រះរាជាណាចក្រកម្ពុជា ត្រូវមានការបញ្ជាក់ជាលាយលក្ខណ៏អក្សរពីក្រសួងបរិស្ថាន ពីភាពត្រឹមត្រូវនៃរាល់ពត៌មានដែលខ្លួនបានផ្តល់ទាក់ទងនឹងសារពាង្គកាយកែច្នៃរស់ត្រូវនាំចេញ ។ លិខិតបញ្ជាក់នេះត្រូវភ្ជាប់ជាមួយនឹងលិខិតអនុញ្ញាតនាំចេញ និងឬ ឯកសារដទៃទៀតទាក់ទងនឹងការវេចខ្ចប់ ការលើកដាក់នាំចេញ ។*

- *មាត្រា ២១ : ម្ចាស់សំណើត្រូវទទួលបន្ទុកក្នុងការវាយតំលៃហានិភ័យ និងទទួលរ៉ាប់រងលើចំណាយទាំងអស់សំរាប់ការវាយតំលៃនេះ ។ នៅពេលបានទទួលលទ្ធផលនៃការវាយតំលៃហានិភ័យ និងឯកសារពាក់ព័ន្ធទាំងឡាយដែលបានតំរូវដោយច្បាប់នេះ ក្រសួងបរិស្ថាននឹងផ្តល់ការឯកភាពជាគោលការណ៏ដោយមាន ឬ គ្មានលក្ខខណ្ឌ ឬ តំរូវអោយផ្តល់ពត៌មានបន្ថែម ឬ បដិសេធមិនផ្តល់ការឯកភាព ។*

## ២-៧ ច្បាប់ស្តីពីព្រៃឈើ

**២០.** ច្បាប់ស្តីពីព្រៃឈើត្រូវបានអនុមត័ដោយរដ្ឋសភាជាតិ និងប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦/៣១ អនុមត័នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០២។ មាត្រាដែលពាក់ព័ន្ធនឹងការវាយតំលៃហេតុប៉ះពាល់បរិស្ថាននៃគំរោងវិនិយោគនេះមានដូចខាងក្រោម :

**<u>មាត្រា១ :</u>**

**២១.** ច្បាប់នេះកំណត់អំពីក្របខ័ណ្ឌនៃការគ្រប់គ្រង ការប្រមូលផល ការប្រើប្រាស់ ការធ្វើអាជីវកម្ម ការអភិវឌ្ឍន៍ និងការអភិរក្សព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ គោលបំណងនៃច្បាប់នេះ គឺធានានូវការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ដើម្បីផលប្រយោជន៍សង្គម-សេដ្ឋកិច្ច និង បរិស្ថាន រួមទាំងការអភិរក្សជីវៈចំរុះ និងមរតកវប្បធម៌។

**<u>មាត្រា៣ :</u>**

**២២.** ការគ្រប់គ្រងព្រៃឈើត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការគ្រប់គ្រងព្រៃលិចទឹកស្ថិតនៅក្រោមច្បាប់មួយដោយឡែក។ រដ្ឋផ្តល់សិទ្ធិគ្រប់គ្រង តំបន់ការពារធម្មជាតិដល់ក្រសួងបរិស្ថាន ក្រោមបទបញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីកិច្ចការពារ បរិស្ថាន និងការគ្រប់គ្រងធម្មជាតិ ចុះនៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ព្រះរាជក្រឹត្យស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ ចុះនៅថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ និងលិខិតបទដ្ឋានច្បាប់ ផ្សេងទៀត។

**២៣.** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិសហការធ្វើសកម្មភាពពង្រឹងការអនុវត្តន៍ច្បាប់ចំពោះរាល់បទល្មើស ព្រៃឈើដែលកើតមាននៅក្នុងតំបន់ការពារធម្មជាតិ ក្រោមការសំរបសំរួលជាមួយក្រសួងបរិស្ថាន ស្របតាមបទបញ្ញត្តិ ដូចមានចែងនៅក្នុងជំពូកទី១៤ នៃច្បាប់នេះ។

**២៤.** សកម្មភាពនេះមិនធ្វើឱ្យប៉ះពាល់ដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដូចចែងក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឡើយ។

**<u>មាត្រា៤</u> :**

- ក្នុងការអនុវត្តច្បាប់នេះ រាល់ការសំរេចរបស់រដ្ឋាភិបាល ដែលមានសក្តានុភាពចំពោះហេតុប៉ះពាល់ធ្ងន់ធ្ងរទៅលើប្រជាពលរដ្ឋទូទៅ លើសហគមន៍មូលដ្ឋាន និងលើធនធានព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានការចូលរួមជាសាធារណៈ។
- សកម្មភាពចំបង១ ដែលពាក់ពន្ធ័ទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ ដែលអាចបណ្តាលឱ្យមានការប៉ះពាល់អាក្រក់ដល់សង្គម និងបរិស្ថាន ចាំបាច់ត្រូវមានការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងហេតុប៉ះពាល់សង្គម ដោយផ្អែកលើក្រុមបច្ចេកទេសគ្រប់គ្រងព្រៃឈើកម្ពុជា និងស្របតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។
- ឯកសារវាយតំលៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ត្រូវផ្តល់ជូនសំរាប់ការចូលរួមផ្តល់មតិជាសាធារណៈ រាល់ការសំរេចចុងក្រោយលើសកម្មភាពចំបង១ពាក់ពន្ធ័ទៅនឹងប្រពន្ធ័មជ្ឈដ្ឋានព្រៃឈើ រាជរដ្ឋាភិបាល ត្រូវពិចារណាលើអនុសាសន៍ចុងក្រោយនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។ ការសំរេចចុងក្រោយ ណាមួយក្រោមមាត្រានេះរាជរដ្ឋាភិបាលអាចជូនដំណឹងជាសាធារណៈ។

**<u>មាត្រា៣៧</u> :**

**២៥.** សហគមន៍មូលដ្ឋានដែលប្រកបរបរចំការពនេចរមានលក្ខណៈប្រពៃណី អាចអនុវត្តលើដីកម្មសិទ្ធិសហគមន៍ជនជាតិភាគតិចដែលបានចុះបញ្ជីការួចហើយជាមួយរដ្ឋ។ ផ្នែករដ្ឋបាលព្រៃឈើនៃមូលដ្ឋាននេះ ត្រូវផ្តល់ការអនុញ្ញាតការគ្រប់គ្រង និងការត្រួតពិនិត្យនៃសកម្មភាពនេះ ដែលជាផ្នែកមួយនៃ ផែនការគ្រប់គ្រងព្រៃសហគមន៍នោះ។ ការអនុវត្តន៍ចំការពនេចរ ត្រូវហាមឃាត់ចំពោះព្រៃធម្មជាតិ មិនទាន់ប៉ះពាល់ក្នុងដែនព្រៃបំរុងទុកអចិន្ត្រៃយ៍។ ដីព្រៃឈើដែលរៀបចំសំរាប់ចំការពនេចរ ត្រូវកំណត់ដោយអនុក្រឹត្យ។

Draft

មាត្រា៩៩ :

២៦. គ្មានរូបវន្តបុគ្គលណាមានសិទ្ធិផ្តល់ការអនុញ្ញាត ទោះបីដោយផ្ទាល់ក្តី ឬដោយប្រយោលក្តីឱ្យកាប់ដើមឈើ ឬធ្វើសកម្មភាពគ្រប់យ៉ាងដើម្បីប្រមូលផល-អនុផលព្រៃឈើ ឬកាន់កាប់ដីក្នុងដែនព្រៃបំរុងទុក អចិន្ត្រៃយ៍ ផ្ទុយនឹងបទបញ្ញត្តិនៃច្បាប់នេះឡើយ ។

មាត្រា៩៤ :

២៧. បុគ្គលណាដែលបានប្រព្រឹត្តបទល្មើសព្រៃឈើ ធ្វើឱ្យប៉ះពាល់ខូចខាតដល់មជ្ឈដ្ឋានព្រៃឈើត្រូវចេញថ្លៃស្តារ ឬជួសជុលការខូចខាតមានលក្ខខ័ណ្ឌដូចដើមឡើងវិញ ។

## ២-៨ ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា

២៨. ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ៣ ។

មាត្រា១ : ច្បាប់នេះមានគោលដៅជំរុញឱ្យមានការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធិភាព និងនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីសំរេចបាននូវការងារអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងសុខមាលភាពរបស់ប្រជាពលរដ្ឋ ។ ច្បាប់នេះកំណត់អំពី :

- សិទ្ធិ និងកាតព្វកិច្ចនៃអ្នកប្រើប្រាស់ទឹក
- គោលការណ៍គ្រឹះសំខាន់ៗ សំរាប់ការគ្រប់គ្រងធនធានទឹក
- ការចូលរួមរបស់សហគមន៍អ្នកប្រើបាស់ទឹក ក្នុងការអភិវឌ្ឍន៍ធនធានទឹកប្រកបដោយនិរន្តរភាព ។

មាត្រា ២ : ក្នុងច្បាប់នេះ ពាក្យបច្ចេកទេសមួយចំនួនមានន័យថា :

- ទឹក គឺទឹកលើដី ទឹកក្រោមដី និងទឹកក្នុងអាកាស ។
- ធនធានទឹក គឺសមុទ្រ ទន្លេ ស្ទឹង ព្រែក ជ្រោះ ជ្រលងជងអូរ បឹងបួ ត្រពាំង ថ្លុក អាងទឹក ។
- ទឹកក្រោមដី គឺទឹកដែលហូរនៅក្រោមដីក្នុងចន្លោះថ្មតូចធំ និងភាគល្អិតនៃដីដែលផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត ។
- ល្អាងទឹកក្រោមដី គឺទឹកក្រោមដីដែលស្ថិតនៅជាអចិន្ត្រៃយ៍ក្នុងល្អាងធម្មជាតិក្រោមដី ។
- អាងទន្លេ គឺតំបន់ភូមិសាស្ត្រដែលកំណត់ដោយព្រំប្រទល់ទីជម្រាលនៃប្រព័ន្ធទឹកហូរ ដោយរាប់បញ្ចូលទាំងទឹកលើដី និងទឹកក្រោមដី ។
- អាងទន្លេរង គឺផ្នែកមួយនៃអាងទន្លេ ។
- ទន្លេអន្តរជាតិគឺទន្លេដែលមានភូមិសាស្ត្រពាក់ព័ន្ធដល់ទឹកដីប្រទេសចាប់ពីពីរឡើងទៅ ។

- ច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក គឺចំណែកដីដែលធម្មតាលិច ដោយទឹកនៅក្នុងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក ដោយរាប់បញ្ចូលទាំងដី ថ្ម ឬអង្គធាតុដទៃទៀតដែលនៅឆ្ងាយពីច្រាំង និងលិចទឹកម្តងម្កាលនោះ។
- ឆ្នេរសមុទ្រ ទន្លេ ស្ទឹង គឺចំណែកដី ឬខ្សាច់ដែលមានសណ្ឋានជម្រាល និងលិចទឹកម្តងម្កាល។
- បាតទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក គឺផ្នែកមួយនៃដីដែលកំណត់ដោយច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹកដែលគ្របដណ្តប់ដោយទឹក។
- តម្រូវការសាធារណៈ គឺការផ្គត់ផ្គង់ទឹកនៅតាមទីក្រុង និងជនបទ ការផលិតស្បៀង ការផលិតថាមពលវារីអគ្គិសនី ការបំរើវិស័យកសិកម្ម វិស័យឧស្សាហកម្ម វិស័យនាវាចរ និងការរក្សាឱ្យមានធារទឹកអប្បបរមា ដើម្បីថែរក្សាបរិស្ថាន ជីវិតមនុស្ស ជីវិតមច្ឆជាតិ និងរុក្ខជាតិនានា។
- ការងារទឹក គឺសំណង់ទំនប់ធំ តូច ទំនប់បង្វៀរ ទំនប់បញ្ចូលទឹក ទំនប់ទឹកការពារ ទឹកជំនន់ ប្រឡាយដោះទឹកធំ តូច ប្រព័ន្ធស្រោចស្រព អាងទឹកធំតូច ប្រឡាយនាំទឹក អណ្តូងទឹកគ្រប់ប្រភេទ ទំនប់វារីអគ្គិសនី និងសំណង់ដទៃទៀត ដែលបានសាងសង់ ក្នុងគោលបំណងបង្វែរទឹក រក្សាទឹកទុក នាំទឹកយកទឹកប្រើប្រាស់ អភិរក្សការពារធនធានទឹក ដោះទឹកចេញពីតំបន់ដីលិចទឹក ការពារកាត់បន្ថយនូវឥទ្ធិពលទឹកជំនន់ និងសង្គ្រោះបន្ទាន់ផ្សេងៗទៀតដែលពាក់ព័ន្ធនឹងទឹក។
- អាជ្ញាបណ្ណ័ទឹក គឺប័ណ្ណដែលផ្តល់សិទ្ធិប្រើប្រាស់ទឹក និងធនធានទឹកឱ្យបុគ្គលគ្រប់រូប ដើម្បីធ្វើអាជីវកម្ម និងអភិវឌ្ឍន៍។
- បុគ្គល គឺរូបវន្តបុគ្គល ឬនីតិបុគ្គល ទោះក្នុងន័យជាឯកជន ឬសាធារណៈក៏ដោយ។

<u>មាត្រា ៣</u> : ទឹក និងធនធានទឹក ជាសម្បត្តិរបស់រដ្ឋ។

<u>មាត្រា ១១</u> : បុគ្គលគ្រប់រូបមានសិទ្ធិប្រើប្រាស់ធនធានទឹកក្នុងបរិមាណមួយ មិនលើសពីសេចក្តីត្រូវការចាំបាច់ជាមូលដ្ឋានសម្រាប់ការហូបចុក បោកគក់ ងូត និងតម្រូវការផ្សេងៗ រួមមានការចិញ្ចឹមសត្វ ការចិញ្ចឹមត្រីការស្រោចស្រពសួនច្បារ និងដំណាំ ដោយចៀសវាងមិនឱ្យមានការប៉ះពាល់ដល់សិទ្ធិស្របច្បាប់របស់អ្នកដទៃ។ តម្រូវការខាងលើនេះ មិនតម្រូវឱ្យសុំអាជ្ញាបណ្ណ័ទឹកឡើយ។

<u>មាត្រា ១២</u> : ការបង្វែរទឹក ការយកទឹក ការប្រើប្រាស់ធនធានទឹក ក្នុងគោលបំណងកសិកម្ម ឬ ឧស្សាហកម្ម លើសពីកំរិតដែលមានចែងក្នុងមាត្រា ១១ និងសំណង់ការងារទឹកដែលពាក់ព័ន្ធ តម្រូវឱ្យមានការសុំអាជ្ញាបណ្ណ័ទឹក ឬលិខិតអនុញ្ញាត។ បែបបទនៃការសុំនេះ និងមានចែងនៅក្នុងអនុក្រឹត្យ។ ការយកខ្សាច់ដី ឬគ្រួសប្រេងកាត និងឧស្ម័នពីបាត ច្រាំង ឆ្នេរ សមុទ្រ ឆ្នេរទន្លេ ស្ទឹង ព្រែក អូរ បឹងបួ តម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណទឹក។

Draft

បែបបទបច្ចេកទេសជលសាស្ត្រដែលពាក់ព័ន្ធនឹងការងារនេះ នឹងមានចែងលំអិតនៅក្នុងអនុក្រឹត្យ។ ការលុបទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ អាងទឹក និងអាងធម្មជាតិ តម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណទឹក ឬលិខិតអនុញ្ញាត។ បែបបទនៃការសុំនេះ នឹងមានចែងនៅក្នុងអនុក្រឹត្យ។ ការសាងសង់ស្ពានតូច ធំ កាត់ទន្លេ ស្ទឹង កំពង់ផែ ឬសំណង់អគារតូច ធំលើច្រាំង និងឆ្នេរតម្រូវឱ្យមានការឯកភាពផ្នែកបច្ចេកទេសជាមុនពីក្រសួងធនធានទឹក និងឧតុនិយម។ ការបង្វែរទឹកពីប្រភពដើមចេញពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានការអនុញ្ញាត និងយល់ព្រមពីរាជរដ្ឋាភិបាលកម្ពុជា ដោយមានការអនុម័តយល់ព្រមពីស្ថាប័ននីតិបញ្ញត្តិ។

<u>មាត្រា ១៤</u> : មុនពេលផ្តល់អាជ្ញាប័ណ្ណទឹកដល់បុគ្គលណាមួយ ក្រសួងធនធានទឹក និងឧតុនិយម ត្រូវពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានលើការប្រើប្រាស់ទឹក និងការសាងសង់ សំណង់ការងារទឹកដែលបុគ្គលនោះស្នើរឡើង។

<u>មាត្រា ២២</u> : រាល់ការបញ្ចេញចោល ការទុកចោល ឬការរក្សាទុកនូវសារធាតុពុលដែលអាចធ្វើឱ្យប៉ះពាល់ដល់គុណភាពទឹក និងអាចបង្កគ្រោះថ្នាក់ដល់មនុស្ស សត្វ និងរុក្ខជាតិ ត្រូវតែសុំអាជ្ញាប័ណ្ណទឹក ឬការអនុញ្ញាត។ ប្រភេទសារធាតុពុលដែលមានចែងខាងលើ និងស្តង់ដារបច្ចេកទេសនៃការបញ្ចេញទឹក សំណល់នឹងមានកំណត់ដោយអនុក្រឹត្យ។ រាល់កិច្ចដំណើរការក្នុងមាត្រានេះ ក្រសួងធនធានទឹក និងឧតុនិយម ត្រូវពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធនានា។

<u>មាត្រា ២៣</u> : ក្រសួងធនធានទឹក និងឧតុនិយម អាចប្រកាសទុកជាតំបន់អាសន្ន ឬជាតំបន់ហាមឃាត់ការប្រើប្រាស់ទឹកក្នុងករណីដែល :

- ទឹកលើដី ឬទឹកក្រោមដីត្រូវបានប៉ះពាល់ផ្នែកបរិមាណ គុណភាព ឬតុល្យភាពអេកូឡូស៊ី។
- ទឹកលើទីជំរាលដែលកំពុងរងការគំរាមកំហែងដោយសកម្មភាពមនុស្ស ឬធម្មជាតិ។
- ទឹកដែលបណ្តាលឱ្យប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ។ ដែនភូមិសាស្ត្រនៃតំបន់អាសន្ន ឬតំបន់ហាមឃាត់នោះ ត្រូវកំណត់តាមករណីនិមួយៗដោយប្រកាស របស់ក្រសួងធនធានទឹក និងឧតុនិយម។

<u>មាត្រា ៣២</u> : រាល់វិវាទដែលពាក់ព័ន្ធនឹងការបង្កើត និងដំណើរការសេវាក្នុងការប្រើប្រាស់ទឹកត្រូវសម្រួលដោះស្រាយដោយក្រសួងធនធានទឹក និងឧតុនិយម ក្រសួងពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន។

<u>មាត្រា ៣៥</u> : រាជរដ្ឋាភិបាលអាចផ្តល់រង្វាន់លើកទឹកចិត្ត ឬភាពអនុគ្រោះផ្សេងៗដល់បុគ្គលទាំងឡាយ ដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវ ការបង្កើតបច្ចេកវិទ្យាថ្មីៗ ឬការដំឡើងឧបករណ៍ទំនើបដែលជួយកាត់បន្ថយកាកសំណល់ និងជួយបង្កើនគុណភាពទឹក ដើម្បីឱ្យការប្រើប្រាស់ទឹកមានប្រសិទ្ធិភាពខ្ពស់។ លក្ខណៈវិនិច្ឆ័យ

និងបែបបទសម្រាប់ការផ្តល់រង្វាន់លើកទឹកចិត្ត ឬភាពអនុគ្រោះផ្សេងៗ ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងធនធានទឹក និងឧតុនិយម ។

**មាត្រា ៣៦** : បទល្មើស និងបញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មដូចតទៅ :

១- ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ពីររយពាន់ (២០០.០០០) រៀល ដល់ពីរលាន (២.០០០.០០០) រៀល ចំពោះបុគ្គលណាដែល :

- រំលោភលើលក្ខខ័ណ្ឌនានាដែលមានកំណត់ក្នុងអាជ្ញាប័ណ្ណទឹក ។
- រារាំងដោយគ្មានមូលហេតុត្រឹមត្រូវ មិនឱ្យមន្ត្រីមានសមត្ថកិច្ចបំពេញនូវតួនាទីរបស់ខ្លួន ។
- សង់សំណង់ធារាសាស្ត្រដោយគ្មានអាជ្ញាបណ្ណ័ទឹក ។

២- ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ពីរលាន (២.០០០.០០០) រៀល ដល់ប្រាំលាន (៥.០០០.០០០) រៀល និងឬដាក់ពន្ធនាគារពីមួយ (១) ខែ ដល់ប្រាំមួយ (៦) ខែ ចំពោះបុគ្គលណា:

- ប្រើប្រាស់ទឹកដោយគ្មានសុំអាជ្ញាប័ណ្ណទឹក ឬលិខិតអនុញ្ញាតិក្នុងករណីដែលច្បាប់តម្រូវឱ្យមាន ។
- ជីក ឬខួងអណ្តូងយកទឹកក្រោមដីធ្វើអាជីវកម្ម ដោយគ្មានអាជ្ញាប័ណ្ណទឹក ។ ប្រាក់ពិន័យនេះនឹងឡើងទ្វេដងកាលណាការជីក ឬខួងអណ្តូងបណ្តាលឱ្យមានការស្រុត ឬបាក់ដី ។ ជនល្មើសត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលបណ្តាលមកពីការស្រុត ឬបាក់ដីនេះ ។

៣- ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ប្រាំលាន (៥.០០០.០០០) រៀល ដល់ដប់លាន (១០.០០០.០០០) រៀល និងឬដាក់ពន្ធនាគារពីមួយ (១) ឆ្នាំ ដល់ប្រាំ (៥) ឆ្នាំ ចំពោះបុគ្គលណា:

- លុបបឹងធម្មជាតិ ស្រះ ត្រពាំង និងអាងទឹកដោយគ្មានលិខិតអនុញ្ញាតិ ។
- បង្ហូរចោលទឹកសំណល់ដែលមានជាតិពុលចូលក្នុងប្រភពទឹកដោយគ្មានអាជ្ញាប័ណ្ណទឹក ។
- ធ្វើសកម្មភាពបំពាននៅក្នុងតំបន់ហាមឃាត់ ។
- បង្កឧបសគ្គ ឬធ្វើឱ្យរាំងស្ទះដល់លំហូរធម្មជាតិនៃទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ ដោយគ្មានការអនុញ្ញាតិ ។
- ធ្វើអាជីវកម្មខ្សាច់ ដី ថ្ម និងក្រួសពីបាតទន្លេ ស្ទឹង ព្រែក និងច្រាំងដោយគ្មានអាជ្ញាប័ណ្ណទឹក ។

៤- គ្រប់ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេមួយជាពីរ ។

**មាត្រា ៣៧** : បុគ្គលណាដែលបង្កអោយមានការខូចខាតដល់សំណង់ការងារទឹកសាធារណៈ នឹងត្រូវទទួលការផ្តន្ទាទោសទៅតាមក្រមព្រហ្មទណ្ឌជាធរមាន ។

Draft

<u>មាត្រា ៣៨</u> : បន្ថែមលើទោសបញ្ញត្តិដូចមានចែងក្នុងមាត្រាខាងលើ ជនល្មើសត្រូវរុះរើចេញនូវប្រភេទសំណង់ដែលខ្លួនបានសាងសង់ និងរៀបចំជូសជុលទីកន្លែងឱ្យបានដូចស្ថានភាពដើមវិញ ហើយឧបករណ៍គ្រឿងចក្រ ដែលពាក់ព័ន្ធនឹងបទល្មើស ត្រូវរឹបអូសជាសម្បត្តិរដ្ឋ។

<u>មាត្រា ៤០</u> : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករ។

## ២-៩ អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

២៩. អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន បានអនុម័តនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៩ ។ អនុក្រឹត្យនេះមានគោលដៅ :

- កំណត់ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន លើរាល់គំរោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតំលៃ ដោយក្រសួងបរិស្ថានមុននឹងដាក់ជូនរាជរដ្ឋាភិបាលសំរេច។
- កំណត់ប្រភេទ និងទំហំគំរោង សកម្មភាពដែលបានស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ទាំងឯកជន ទាំងសាធារណៈ ដែលត្រូវវាយតំលៃហេតុប៉ះពាល់បរិស្ថាន។
- បំផុសឱ្យមានការចូលរួមពីសាធារណៈជនក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងទទួលយកមតិយោបល់មកធ្វើការពិចារណា ក្នុងកិច្ចដំណើរការអនុម័តគំរោង ។

៣០. យោងតាមឧបសម្ព័ន្ធនៃអនុក្រឹត្យនេះផងដែរ ក៏មានការចាត់ថ្នាក់ពីប្រភេទគំរោងដែលទាក់ទងទៅនឹងវិស័យឧស្សាហកម្មត្រង់ចំណុច ១.៦.៧ សំរាប់ផ្នែកផលិតផលពីរ៉ែ មិនមែនជាលោហៈ ដែលទាមទារឱ្យម្ចាស់ក្រុមហ៊ុនរៀបចំរបាយការណ៍ IEIA ឬ EIA លើគំរោងធ្វើអាជីវកម្មរ៉ែ។

## ២-១០ អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក

៣១. អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក បានអនុម័តនៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៩ ។ អនុក្រឹត្យនេះ :

- មានគោលដៅ កំណត់ការត្រួតពិនិត្យការបំពុលទឹក ដើម្បីទប់ស្កាត់ និងកាត់បន្ថយការ បំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ សំដៅធានាបានការការពារសុខភាពមនុស្ស និងការអភិរក្សជីវចំរុះ
  - មានវិសាលភាពអនុវត្តចំពោះរាល់ប្រភពបំពុល និងរាល់សកម្មភាពទាំងឡាយ ដែលបង្កឱ្យមានការបំពុលទឹក នៅតាមតំបន់ទឹកសាធារណៈ។

៣២. ពាក់ព័ន្ធទៅនឹងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក ក្នុងក៏រិតកំណត់ស្តង់ដារនៃការបញ្ចេញសំណល់រាវ ពីប្រភពបំពុលចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬទៅក្នុងប្រព័ន្ធបណ្តាញលូ។

Draft

**តារាងទី២-១ :** កំរិតកំណត់ស្តង់ដារនៃការបញ្ចេញសំណល់រាវ ពីប្រភពបំពុលចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬនៅក្នុងប្រព័ន្ធបណ្តាញលូ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | បរិមាណសារធាតុបំពុលដែលអាចអនុញ្ញាតឱ្យបញ្ចេញ | |
|---|---|---|---|---|
| | | | តំបន់ទឹកសាធារណៈដែលត្រូវបានការពារ | តំបន់ទឹកសាធារណៈនិងលូ |
| 1 | Temperature | 0C | < 45 | < 45 |
| 2 | pH | - | 6 – 9 | 5 – 9 |
| 3 | BOD5 ( 5 days at 200 C ) | mg/l | < 30 | < 80 |
| 4 | COD | mg/l | < 50 | < 100 |
| 5 | Total Suspended Solids | mg/l | < 50 | < 80 |
| 6 | Total Dissolved Solids | mg/l | < 1000 | < 2000 |
| 7 | Grease and Oil | mg/l | < 5.0 | < 15 |
| 8 | Nitrate (NO3 ) | mg/l | < 10 | < 20 |
| 9 | Sulphate ( as SO4 ) | mg/l | < 300 | < 500 |
| 10 | Sulphide ( as Sulphur ) | mg/l | < 0.2 | < 1.0 |
| 11 | Phosphate ( PO4 ) | mg/l | < 3.0 | < 6.0 |
| 12 | Cyanide ( CN ) | mg/l | < 0.2 | < 1.5 |
| 13 | Barium ( Ba ) | mg/l | < 4.0 | < 7.0 |
| 14 | Arsenic ( As ) | mg/l | < 0.10 | < 1.0 |
| 15 | Tin ( Sn ) | mg/l | < 2.0 | < 8.0 |
| 16 | Iron ( Fe ) | mg/l | < 1.0 | < 20 |
| 17 | Manganese ( Mn ) | mg/l | < 1.0 | < 5.0 |
| 18 | Cadmium ( Cd ) | mg/l | < 0.1 | < 0.5 |
| 19 | Chromium ( Cr )+3 | mg/l | < 0.2 | < 1.0 |
| 20 | Chromium ( Cr )+6 | mg/l | < 0.05 | < 0.5 |
| 21 | Copper ( Cu ) | mg/l | < 0.2 | < 1.0 |
| 22 | Lead ( Pb ) | mg/l | < 0.1 | < 1.0 |
| 23 | Mercury (Hg ) | mg/l | < 0.002 | < 0.05 |

Draft

| | | | | |
|---|---|---|---|---|
| 24 | Nickel ( Ni ) | mg/l | < 0.2 | < 1.0 |
| 25 | Silver ( Ag ) | mg/l | < 0.1 | < 0.5 |
| 26 | Zinc ( Zn ) | mg/l | < 1.0 | < 3.0 |
| 27 | Molybdenum ( Mo ) | mg/l | < 0.1 | < 1.0 |
| 28 | Ammonia ( NH3 ) | mg/l | < 5.0 | < 7.0 |

៣៣. ពាក់ព័ន្ធទៅនឹងឧបសម្ព័ន្ធទី៤.១ នៃអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក ក្នុងកំរិតកំណត់ស្តង់ដារ គុណភាពនៅតាមតំបន់ទឹកសាធារណៈ សំរាប់អភិរក្សជីវៈចំរុះនៅក្នុងទឹកទន្លេ។

**តារាងទី២-២** : កំរិតកំណត់ស្តង់ដារគុណភាពនៅតាមតំបន់ទឹកសាធារណៈ
សំរាប់អភិរក្សជីវៈចំរុះនៅក្នុងទឹកទន្លេ

| ល.រ | ប៉ារ៉ាម៉ែត្រ | ឃ្នាត | កំរិតស្តង់ដា |
|---|---|---|---|
| 1 | pH | - | 6.5 – 8.5 |
| 2 | BOD5 | mg/l | 1 – 10 |
| 3 | សារធាតុរឹងអណ្តែតក្នុងទឹក (SS) | mg/l | 25 – 100 |
| 4 | កំរិតរលាយអុកស៊ីសែន (DO) | mg/l | 2.0-7.5 |
| 5 | កូលីហ្វម (Coliform) | MPN/100ml | <5000 |

## ២-១១ អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង

៣៤. អនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំណល់រឹង បានអនុម័តនៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៩។ អនុក្រឹត្យនេះ :

- មានគោលដៅ កំណត់ការគ្រប់គ្រងសំណល់រឹង ប្រកបដោយលក្ខណៈបច្ចេកទេសសមស្រប និង ប្រកបដោយសុវត្ថិភាព សំដៅធានាបាននូវការការពារសុខភាពសាធារណៈ គុណភាពបរិស្ថាន និង ការអភិរក្សជីវចំរុះ
- មានវិសាលភាពអនុវត្ត ចំពោះរាល់សកម្មភាពបោះចោល ទុកដាក់ ស្តុក ប្រមូល ដឹកជញ្ជូន កែច្នៃ និង បញ្ចេញចោលសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់
- មានភ្ជាប់ជាមួយនូវឧបសម្ព័ន្ធ ដែលកំណត់នូវប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់ ។

Draft

## ២-១២ អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង

៣៥. អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង បាន អនុម័តនៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០ ។ អនុក្រឹត្យនេះ

- កំណត់ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង ដើម្បីទប់ស្កាត់ និងកាត់បន្ថយសារធាតុដែលបំពុលខ្យល់ និងសំលេងក្នុងបរិយាកាស សំដៅការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈ
- មានវិសាលភាពអនុវត្ត និងចាត់វិធានការណ៍ ចំពោះរាល់ប្រភពបំពុលចល័ត និងអចល័តទាំង ឡាយដែលបង្កឱ្យមានការបំពុលខ្យល់ និងការរំខានដោយសំលេងនៅក្នុងបរិយាកាស ។

៣៦. ពាក់ព័ន្ធទៅនឹងឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង ក្នុងកំរិតកំណត់ស្តង់ដារគុណភាពខ្យល់ ។

**តារាងទី២-៣** : កំរិតកំណត់ស្តង់ដារគុណភាពខ្យល់

| Nº | ប៉ារ៉ាម៉ែត្រ | រយៈពេល 1ម៉ោង mg/m³ | រយៈពេល 8ម៉ោង mg/m³ | រយៈពេល 24ម៉ោង mg/m³ | រយៈពេល 1ឆ្នាំ mg/m³ |
|---|---|---|---|---|---|
| 1 | Carbon monoxide (CO) | 40 | 20 | - | - |
| 2 | Nitrogen dioxide ($No_2$) | 0.3 | - | 0.1 | - |
| 3 | Sulfur dioxide ($SO_2$) | 0.5 | - | 0.3 | 0.1 |
| 4 | Ozone ($O_2$) | 0.2 | - | - | - |
| 5 | Lead (Pb) | - | - | 0.005 | - |
| 6 | Total Suspended Particulate (TSP) | - | - | 0.33 | 0.1 |

៣៧. ពាក់ព័ន្ធទៅនឹងឧបសម្ព័ន្ធទី៧ នៃអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និង ការរំខានដោយសំលេង ក្នុងកំរិតកំណត់ស្តង់ដារ សំរាប់ត្រួតពិនិត្យសំលេង ក្នុងទីតាំងរោងជាង រោងចក្រឧស្សាហកម្ម ។

**តារាងទី២-៤** : កំរិតកំណត់ស្តង់ដាសំរាប់ត្រួតពិនិត្យសំលេង ក្នុងទីតាំងរោងជាង រោងចក្រឧស្សាហកម្ម

| កំរិតសំលេង dB(A) | រយៈពេលអតិបរមា (ម៉ោង) | កំណត់បង្ហាញ |
|---|---|---|

Draft